ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*******

តុលាការកំពូល
សភាផ្នែកព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ០២
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩
សាលដីកា
លេខ : ១៤
ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ ៖

| | | | |
|---|---|---|---|
| ១_ | ឯកឧត្តម | ឌិត មុន្ទី | ជាប្រធាន |
| ២_ | លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣_ | លោក | សោម សិរីវឌ្ឍ | ចៅក្រម_របាយការណ៍ |
| ៤_ | លោក | ប្រាក់ គីមសាន | ចៅក្រម |
| ៥_ | លោក | យស់ សូខឿន | ចៅក្រម |
| | | ក្រឡាបញ្ជី | |
| | លោក | ប៉ុល វណ្ណា | |
| | | តំណាងមហាអយ្យការ | |
| | លោក | ជួន ស៊ុនឡេង | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌ២៨០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍និងសំណុំរឿងព្រហ្មទណ្ឌលេខ០២ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

ពីបទ : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែមេសា ឆ្នាំ១៩៩៨ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបុញ្ញត្តិមាត្រា៤៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០_៩_១៩៩២ ។

១_ ជនជាប់ចោទឈ្មោះហៀ រ៉ាត តេរីណោ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិចារាំង របររកស៊ី ធ្វើជាចុងភៅ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ១៣អា ផ្លូវលេខ២២២ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ

តេរីណោ ម៉ូរីស(រ) ម្តាយឈ្មោះរ៉ាបា តែល(រ) ប្រពន្ធឈ្មោះចាន់ថូដា មានកូន២នាក់ ។ ក្រៅឃុំ ។

+ មេធាវី គ្មាន ផ្ទេរសិទ្ធិឱ្យលោកម្លូង សុទ្ធី

_ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះដានីញ៉ែល_សារីយ៉ាលី(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិបារាំង របររកស៊ីពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ៣៧៩ ផ្លូវស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

+ មេធាវី គ្មាន .

_ តាមបណ្តឹងសាទុក្ខលេខ០១ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៩ របស់លោកហ្សេរ៉ា តេរីណោ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២៨០ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

_ តាមពាក្យបណ្តឹងចុះថ្ងៃទី២២_៤_៩៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះដារីញ៉ែល ប្តឹងពីឈ្មោះហ្សេរ៉ាត តេរីណោ និងប្រពន្ធឈ្មោះចាន់ថូដា ពីបទរំលោភលើសេចក្តីទុកចិត្ត ដោយហេតុថា ខ្លួននិងឈ្មោះហ្សេរ៉ាត តេរីណោ បានដាក់ហ៊ុនគ្នាបើកភោជនីយដ្ឋានមួយឈ្មោះឡាតារ៉ែន ។ ក្រោយមកក៏មានទំនាស់គ្នាឈ្មោះហ្សេរ៉ាត តេរីណោ បានបណ្តេញខ្លួនចេញពីភោជនីយដ្ឋាន ទើបខ្លួនដាក់ពាក្យប្តឹងទៅតុលាការ ដើម្បីសុំចែកភាគហ៊ុន ។

_ បានឃើញដីកាសំរេចឱ្យជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្នលេខ ៦០៦៣គុ_ព្រចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ដែលបានសំរេច ៖

១_ ឱ្យឈ្មោះហ្សេរ៉ាត តេរីណោ អាយុ៤៥ឆ្នាំ ភេទប្រុស ជាតិបារាំង របររកស៊ីចុងភៅភោជនីយដ្ឋាន មានទីលំនៅផ្ទះលេខ៣៧៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដែលជាប់ចោទពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែមេសា ឆ្នាំ១៩៩៨ ហើយដែលត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងក្រុងភ្នំពេញ លេខ៦៩៩ ចុះថ្ងៃទី០៥_១១_១៩៩៩ នៅក្រៅឃុំបណ្តោះអាសន្ន ។

២- បង្គាប់មកលោកប្រធានមន្ទីរឃុំឃាំងទីមួយនៃក្រសួងមហាផ្ទៃ ឱ្យដោះលែងឈ្មោះនេះជាបន្ទាន់ ប្រសិនបើឈ្មោះនេះមិនបានត្រូវឃុំខ្លួន ពីបទល្មើសផ្សេងទៀតទេ តែត្រូវឱ្យឈ្មោះនេះចូលទៅកាន់តុលាការជាដរាបកាលបើមានដីកាកោះហៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ៨២(ក)ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨របស់ឈ្មោះដានីញ៉ៀល សារីយ៉ាលី ដែលប្តឹងតវ៉ាពីដីកាសំរេចឱ្យជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្នលេខ៦០៦៣គុ-ព្រ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថាៈសុំឱ្យក្រុមប្រឹក្សាជំនុំជំរះ មេត្តាសំរេចតាមច្បាប់ផងចុះ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៨០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦-១១-៩៨ របស់ឈ្មោះដារីញ៉ៀល សារីយ៉ាលី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធដីកាសំរេចឱ្យជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ៦០៦៣គ-ព្រ ចុះថ្ងៃទី១៣-១១-៩៨ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣- សំរេចឃុំខ្លួនឈ្មោះហ្សេរ៉ាត តើរីណោ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិបារាំង ជាបណ្តោះអាសន្នសិន ។

៤- បង្គាប់ឱ្យចាប់ខ្លួនឈ្មោះហ្សេរ៉ាត តើរីណោ មកឃុំខ្លួនជាបណ្តោះអាសន្នសិន ។

៥- សាលដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៦- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីកំបាំងមុខជនជាប់ចោទបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៨របស់ឈ្មោះហេង្សរ៉ាត តេរីណេ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២៨០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះហេង្សរ៉ាត តេរីណេ ( ជាម្ចាស់បណ្តឹងសាទុក្ខ )ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩របស់ឈ្មោះដានីញៀល សារីយ៉ាញៀល ( ជាចុងបណ្តឹងសាទុក្ខ ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់អំណានសារតាជាតិជនជាប់ចោទឈ្មោះហេង្សរ៉ាត តេរីណេ (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

- បានស្តាប់អំណានសារតាជាតិដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះដានីញៀល-សារីយ៉ាលី (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា ៖

១- បណ្តឹងសាទុក្ខរបស់មេធាវីការពារឱ្យជនជាប់ចោទធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

២- បដិសេធសាលដីកាព្រហ្មទណ្ឌលេខ២៨០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់អំណានសារណារបស់ឈ្មោះហេង្សរ៉ាត តេរីណេ (ជាម្ចាស់-បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

- បានស្តាប់អំណានសារណាតបរបស់ឈ្មោះ ដានញៀលី , សារីយ៉ាលី (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា សុំរក្សាសេចក្តីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទនិងរបស់ដើមបណ្តឹងរដ្ឋប្បវេណី .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ០១ ចុះថ្ងៃទី៦-១-៩៩របស់លោកហ្សេរ៉ាត តេរីណេ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាលោកហ្សេរ៉ាត តេរីណេ ត្រូវបានចោទប្រកាន់អំពីបទល្មើសរំលោភលើសេចក្តីទុកចិត្តកាលពីខែមេសា ឆ្នាំ១៩៩៨ នៅក្រុងភ្នំពេញ ដែលជាបទល្មើសមជ្ឈឹម ។

- យល់ឃើញថាការដែលសាលាឧទ្ធរណ៍បានយល់ឃើញថា ដីកាសំរេចឱ្យជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្នលេខ៦០៦៣គ-ព្រ ចុះថ្ងៃទី១៣-១១-៩៨របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេចមកនេះ ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីបដិសេធចោល នោះគឺជាការភ័ន្តច្រឡំ ។

- យល់ឃើញថាលោកហ្សេរ៉ាត តេរីណេ ជាជនបរទេសមានប្រពន្ធកូនបច្ចុប្បន្នរស់នៅរកស៊ីនៅខេត្តសៀមរាប ថ្វីត្បិតមិនបានដាក់ប្រាក់ធានាក្តី ក៏លោកហ្សេរ៉ាត-តេរីណេបានដាក់ PASSPORT ធានារួចមកហើយដែរ ដែលបញ្ជាក់ថាលោកហ្សេរ៉ាត តេរីណេ មិនអាចចេញពីស្រុកខ្មែរបានឡើយ ។

- យល់ឃើញថាជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាជូនមកតុលាការកំពូលហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកទាំងពីរ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ២៨០ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ១ ចុះថ្ងៃទី៦-១-៩៩ របស់លោក ហេង្សរ៉ាត គើរីណោ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២៨០ចុះថ្ងៃទី២៥-១២-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៣- អនុញ្ញាតឱ្យជនជាប់ចោទឈ្មោះហេង្សរ៉ាត គើរីណោ នៅក្រៅឃុំ ជាបណ្តោះអាសន្ន ។

៤- បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២ ចុះថ្ងៃទី១១-១-៩៩ របស់ តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការបន្ត ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ៕